# ការសម្ភាសរបស់លោក ហ៊ុន ឡេង

**កៈ អ្នកសម្ភាសឈ្មោះ ឡេង ធាវី ខៈ អ្នកត្រូវគេសម្ភាសឈ្មោះ ហ៊ុន ឡេង**
**គៈ ញ៉ែម សុគន្ធា**

កៈ ខ្ញុំថ្លែងអំណរគុណដល់ប៉ា ដែលឲ្យសម្ភាសអំពីជីវប្រវត្តិ ។ ខ្ញុំឈ្មោះ ឡេង ធាវី ជាអ្នកសម្ភាស ។ ប៉ាឈ្មោះពេញ ឈ្មោះអីគេ?

ខៈ ឈ្មោះ ហ៊ុន ឡេង ។ ហ៊ុន ឡេង

កៈ ថ្ងៃនេះខ្ញុំសម្ភាស គឺនៅក្នុងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៦ ។ ការសម្ភាសនេះត្រូវបានរៀប ចំឡើងដោយសាកលវិទ្យាល័យនៅប្រទេសអាមេរិក ឈ្មោះថា BYU ។ សាកលវិទ្យាល័យ មានកម្មវិធីដើម្បីសម្ភាសអំពីជីវប្រវត្តិរបស់ប៉ានិងប្រជាជនខ្មែរ ដើម្បីពេលអនាគត សម្ភាសអំពី... ទៅមុខ ទៅកូនចៅរបស់ប៉ា និងមនុស្សជំនាន់ក្រោយឲ្យដឹងពីជីវប្រវត្តិ និងដំណើររឿង ឆាកជីវិតរបស់ដូនតា ។ តើប៉ាអនុញ្ញាតឲ្យខ្ញុំដាក់ ការសម្ភាសនេះចូលទៅក្នុងវេបសាយរបស់សាកលវិទ្យាល័យ BYU ដែរឬទេ?

ខៈ អនុញ្ញាតឲ្យដាក់បាន អូខេ!

កៈ វេបសាយនេះមានឈ្មោះថា www.cambodianoralhistory.byu.edu ។ ខ្ញុំសូមចាប់ផ្ដើមធ្វើការសម្ភាសន៍នេះ ។ តើប៉ា... សូមប្រាប់ឈ្មោះពេញម្ដងទៀត

ខៈ ឈ្មោះ ហ៊ុន ឡេង

កៈ តើប៉ាមានគេ...មានឈ្មោះហៅក្រៅដែរឬទេ?

ខៈ មានដែរ ហៅថាទុំទាវ «សើច»

កៈ តើប៉ាកើតនៅថ្ងៃទី... ថ្ងៃណា ខែណា ឆ្នាំណា?

ខៈ កើតនៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៩៦១។

កៈ ទីកន្លែងកំណើតរបស់ប៉ានៅឯណា?

ខៈ នៅឯភូមិក្រឡា ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

កៈ តើប៉ាកើតនៅឆ្នាំហ្នឹង ត្រូវជាឆ្នាំសត្វអ្វី?

ខៈ ឆ្នាំសត្វគោ ឆ្នាំឆ្លូវ បុរាណខ្មែរថាឆ្នាំឆ្លូវ។

កៈ តើប៉ាមានបងប្អូនប្រុសស្រីប៉ុន្មាននាក់?

ខៈ មានបងប្អូនទាំងអស់៥នាក់ ស្រី២ ប្រុស៤ ។ អូ ! តែ៦នាក់ ។ មាន៦នាក់ ប្រុស៤ ស្រី២... ច្រឡំ។

កៈ តើប៉ាជាកូនទីប៉ុន្មាន?

ខៈ ប៉ាជាកូនទី១ កូនច្បងគេ។

កៈ តើឥឡូវនេះបងប្អូនរបស់ប៉ាទាំងអស់រស់នៅទាំងអស់ដែរឬទេ?

ខៈ ពួកគាត់រស់នៅទាំងអស់គ្នា ប៉ុន្តែរស់នៅបែកពីគ្នា បែកពីប៉ាហើយ ខ្លះនៅឯខេត្តក្រចេះទៅ ខ្លះនៅឯខេត្តសៀមរាបទៅ ខ្លះនៅឯស្រុកកំណើត នៅខ្លះទៅ។

កៈ តើលោកតាឈ្មោះអ្វី?

ខៈ លោកតាឈ្មោះ ណោ ហ៊ុន

កៈ តើទីកន្លែងកំណើតគាត់នៅឯណា?

ខៈ ទីកន្លែងកំណើតគាត់នៅភូមិក្រឡា ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាមហ្នឹង។

កៈ តើគាត់កើតនៅថ្ងៃណា ខែណា ឆ្នាំណា?

ខៈ អូ! ភ្លេចបាត់ទៅហើយ ថ្ងៃកំណើត... សំបុត្រកំណើតគាត់ អីគាត់ អូ! មិនអាចចាំបានទេ ក្នុងនេះគេមានតែឈ្មោះឪពុកម្តាយ គ្រាន់តែក្នុងបញ្ជីជាតិ គេដាក់ឈ្មោះថា ណោ ហ៊ុន ហ្នឹង ជាតិខ្មែរ កើតនៅឆ្នាំ១៩៣២។

កៈ តើប៉ាមានការចងចាំអ្វីខ្លះជាមួយគាត់?

ខៈ អូ! ប៉ាចងចាំជាមួយគាត់ គឺចងចាំច្រើន មិនអាចរៀបរាប់ពេលខ្លីបានទេ ព្រោះថាយើងរស់នៅជាមួយគាត់២០ឆ្នាំជាងណោះ ប៉ុនប៉ាចងចាំជាងគេគឺថាឪពុកដ៏ល្អ កាលហ្នឹង ហៅប៉ាថា អាប្រុសៗរហូត តាំងពីដើមមក គាត់មិនដែលបានវាយទេ គាត់ជាឪពុកដ៏ល្អមួយ ស្រលាញ់កូនណាស់ ។

កៈ តើឆ្នាំកំណើតគាត់ជាសត្វអ្វី?

ខៈ តា បើខ្ញុំគិតពីឆ្នាំកំណើតគាត់ ប៉ាចាំថាដូចជាឆ្នាំ សត្វស្វា ឆ្នាំវក។

កៈ តើតាគាត់ស្លាប់ឬក៏រស់?

ខៈ គាត់ស្លាប់ហើយ គាត់ស្លាប់នៅក្នុងអាយុ៧៨ឆ្នាំ នៅឆ្នាំ២០០៦គាត់ស្លាប់។

កៈ តើយាយមានឈ្មោះអ្វី?

ខៈ យាយមានឈ្មោះថា គ្រី ឃីម។ គាត់មានឆ្នាំកំណើតនៅឆ្នាំ១៩៣០ ។

កៈ ប៉ាចាំថាគាត់កើតនៅកន្លែងណា?

ខៈ ប៉ាមិនចាំច្បាស់ណាទេ គាត់កើត ប៉ុន្តែថាកើត... ធំឡើងជាមួយគាត់នៅឯ... គេហៅថាភូមិមួយនោះ គេហៅថាភូមិទ្រាន ឃុំទ្រាន ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

គៈ ចុះនៅក្នុងសំបុត្រកំណើតគេដាក់ថ្ងៃណាវិញលោកពូ?

ខៈ ក្នុងសំបុត្រកំណើតនេះគេដាក់ទៅក្នុងស្រុកកំណើតខាងប៉ាហ្នឹង កាលហ្នឹងប៉ូលីសគេចេះតែចុះទៅ មិនបានរ៉ាយរ៉ាប់អីណាយើងប្រាប់អីច្បាស់លាស់ផងហ្នឹង។ ចេះតែចុះតាមៗគ្នាទៅ ពួកប៉ូលីសហ្នឹងហ្នំ។

កៈ តើគាត់មានឆ្នាំកំណើតជាសត្វអ្វី?

ខៈ យាយ បើតាមប៉ាចាំ គាត់មានឆ្នាំកំណើតដូចជាឆ្នាំ...អីទេមើល...ឆ្នាំកុរយ៉ាង... ឆ្នាំជ្រូក។

កៈ តើគាត់ស្លាប់ឬក៏រស់?

ខ៖ ឥឡូវហ្នឹងគាត់ស្លាប់ហើយ។ គាត់ស្លាប់ក្នុងអាយុ៨១ឆ្នាំ ស្លាប់នៅឆ្នាំ២០១៣ចឹងហើយ កាលណុង។ បាទ! ហ្នឹង២០១៣ ចឹងហើយ។

ក៖ តើប៉ាមានការចងចាំអីខ្លះជាមួយយាយ?

ខ៖ អូ! យាយ ចងចាំល្អណាស់ជាមួយគាត់ ព្រោះថាយើងរស់នៅជាមួយឪពុកម្ដាយ ម្ដាយស្និតស្នាលជាងឪពុក។ ម្ដាយគាត់... គាត់អឺ...គាត់អាវែងរស់នៅជាមួយយើងយ៉ាងជាប់លាប់ ហើយគាត់ស្រលាញ់យើង ថ្នាក់ថ្នមយើង គាត់មិនដែលឲ្យយើងពិបាកចិត្តឲ្យគាត់ទេ គាត់ជាម្ដាយមួយដ៏ល្អ ថ្វីត្បិតតែគាត់មិនបានទទួលការអប់រំរៀនសូត្របានច្រើនមែន ប៉ុន្តែគាត់មានទឹកចិត្តជាម្ដាយល្អ វិសេសវិសាលមួយ ។

ក៖ តើតារបស់ប៉ាឈ្មោះអ្វី?

ខ៖ តារបស់ប៉ាឈ្មោះគាត់ហៅថា ភឹង ណោ។ ឈ្មោះ កុង(តា) ណោ ហៅក្រៅ។

ក៖ តើគាត់កើតនៅថ្ងៃ ខែ ឆ្នាំណា? ប៉ាចាំទេ?

ខ៖ អូ! ប៉ាមិនចាំទេ រឿងថ្ងៃ ខែ ឆ្នាំកំណើតរបស់ កុង ណោ ហ្នឹងហ្ន៎ ព្រោះប៉ាកើតមកគាត់ ចាស់ហើយណុង។

ក៖ តើប៉ាមានស្គាល់កន្លែងទីកំណើតរបស់គាត់ទេ?

ខ៖ ទីកំណើតរបស់គាត់នៅស្រុក ភូមិក្រឡា ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ពេលបច្ចុប្បន្នហ្នឹង។ អាហ្នឹងគឺស្រុកកំណើតខាងកុង ហ៊ុនហ្នឹង ហើយនិង កុង ណោហ្នឹងឯង។ គាត់រស់នៅហ្នឹង។

ក៖ ប៉ាចាំថាគាត់ឆ្នាំអី សត្វអី?

ខ៖ អត់ចាំទេ ព្រោះប៉ានៅតូចកាលណុងហ្ន៎។

ក៖ ហើយគាត់ស្លាប់ឬក៏គាត់រស់ឥឡូវហ្នឹង?

ខ៖ គាត់ស្លាប់ហើយ ស្លាប់តាំងពីឆ្នាំ១៩៧៧ម៉េះ ស្លាប់ក្នុងសម័យ ប៉ុល ពត ។ ស្លាប់យ៉ាង... ហៅថាអាណោចអាធម្មនៅក្នុងសម័យ ប៉ុល ពត ព្រោះថាវាស្លាប់ នៅក្នុងអាវែងហៅថា... ហៅថារបបប្រល័យពូជសាសន៍។

ក៖ ហើយប៉ាមានការចងចាំអីជាមួយគាត់នេះ?

ខ៖ អូ! ពីតូច ប៉ាធ្លាប់ដើរជាមួយគាត់នៅឯខ្ទមស្រែ។ គាត់អ្នកពូកែធ្វើការណាស់ កិច្ចការងារ ភ្ជួររាស់ស្រែចម្ការ កិច្ចការងារអីគាត់អ្នកឆ្លាតវៃក្នុងកិច្ចការណាស់។ គាត់ពូកែណាស់ ហើយ គាត់មានចិត្តស្រលាញ់កូនចៅទាំងអស់គ្នា ។

ក៖ ចុះតើយាយរបស់ប៉ាឈ្មោះអី?

ខ៖ អូ! យាយរបស់ប៉ាហ្នឹង ប៉ាកើតមិនទាន់ទេ គាត់ស្លាប់តាំងពីអាវែងអាយុ...តាំងពីប៉ា កុង ហ៊ុនហ្នឹងនៅអាយុប្រហែលជាប្រាំពីរ ប្រាំបីឆ្នាំអីម៉េះ ស្លាប់ទៅយូរហើយ យាយហ្នឹង។ ប៉ា កើតមកទាន់ឃើញថាក្រោយ យាយក្រោយ គេហៅប្រពន្ធក្រោយរបស់កុងហ្នឹងទេ។ ប្រពន្ធគាត់ហ្នឹងឈ្មោះ យាយ លីន។ ប៉ុនឥឡូវគាត់ៗស្លាប់អស់ហើយ! ចាស់ៗអស់ហើយ។

ក៖ ចុះប៉ាមានស្គាល់ថ្ងៃ ខែ ឆ្នាំកំណើតគាត់ឬក៏គាត់កើតឆ្នាំសត្វអី?

ខ៖ ប៉ាមិនអាចស្គាល់បានទេ រឿងឆ្នាំកំណើតគាត់ ព្រោះពួកយើង អត់បានចាប់អារម្មណ៍ នឹកនាអីទៅរកគាត់ផងហ្នឹង។ យើងគ្រាន់តែជាការរស់នៅជាមួយគាត់ ធ្លាប់ដើរហើរអីជាមួយគាត់ ធ្លាប់ធ្វើការ ជួយធ្វើការអីគាត់ហ្នឹងហ្នាស។

ក៖ ហើយប៉ាមានការចងចាំអីខ្លះជាមួយគាត់អត់?

ខ៖ ប៉ាគ្រាន់តែចងចាំថាជីដូនជីតាខាងកុងហ្នឹងក៏ជាមនុស្សគួរឲ្យស្រលាញ់ណាស់។ គាត់ស្រលាញ់កូនចៅ គាត់ពូកែធ្វើការងារ គាត់ឧស្សាហ៍ មិនដែលហ៊ានខ្ជិលអីទេ តែយើងដាស់តឿនកូនចៅហ្នឹងឲ្យប្រឹងប្រែងធ្វើការងារ រកស៊ីចិញ្ចឹមជីវិតហ្នឹង។

ក៖ អ៊ីចឹងទាំងតា ទាំងយាយ ទាំងកុងទួត យាយទួតអី ដែលធ្លាប់ទៅនៅប្រទេសក្រៅអត់?

ខ៖ «សើច» សើចមួយចុះ សើចឱ្យបន្ធូរបរិយាកាសតានតឹងហើយនិងនឹកឃើញដល់អតីត កាល។ ពួកគាត់មិនដែលទៅរស់នៅប្រទេសក្រៅអីទេ។ គាត់រស់នៅតែស្រុកកំណើតគាត់ហ្នឹង

អស់ក្បាច់ហើយគាត់មកលេងទីរួមខេត្តអីហ្នឹង ហើយក៏ទៅលេងភ្នំពេញអីហួស់ប៉ុណ្ណឹង។ គាត់រស់នៅតែក្នុងប្រទេសខ្មែរហ្នឹង។ ចាប់ពីដើមគាត់មិនសូវសម្បុរអារ៉ែងរឿងមធ្យោបាយធ្វើដំណើរ គាត់ច្រើនតែរស់ទីណាគាត់ទៅទីណុង។ ទាល់តែកូនចៅគេ ហៅទៅក៏មានរវល់ កិច្ចការអី បានគាត់រកអារ៉ែងធ្វើដំណើរទៅឆ្ងាយៗទៅ តាមមធ្យោបាយឡានឈ្នួលអីចឹងទៅ។

ក៖ កាល... ឥឡូវប៉ារៀនថ្នាក់ទីប៉ុន្មានអី? កាលរៀន រៀនដល់ថ្នាក់ទីប៉ុន្មានប៉ា?

ខ៖ បើនិយាយពីប្រវត្តិរៀនសូត្ររបស់ប៉ា ប៉ារៀនចប់អត់ចប់សាលាបឋមផងហ្នឹង។ ទទួលសម័យស្រុកសង្គ្រាម គេច្បាំងគ្នា គេជម្លៀសប្រជាជនចេញពីទីលំនៅ ពួក ប៉ុល ពត ហ្នឹងគេកៀរអីចឹងទៅ សាលារៀនត្រូវបិទទ្វារ ប្រទេសជាតិ ត្រូវធ្លាក់នៅក្នុងសង្គ្រាមពីម្ខាងទៅ ឈ្លោះទាស់ទែង ប្រជែងដណ្តើមទឹកដីគ្នា ដូច្នេះយើងអត់បានរៀនទេ។ ក្រោយពីសម័យ សង្គ្រាមហ្នឹងមក សម័យ ប៉ុល ពតហ្នឹង ប៉ារៀនបានតែប្រហែលជាកន្លះឆ្នាំអីទៀត គេថាយើង ធំហើយយើងល្មមទៅធ្វើការ កើបអាចម៍គោអី កងកុមារអីចឹងទៅ កូនចល័តអីចឹងទៅ រៀនរហូត អីធ្វើការរហូត មានបានរៀនអី។

ក៖ អីចឹង កាលប៉ាឯងរៀន រៀននៅសាលាបឋមសិក្សាអីគេ?

ខ៖ ប៉ារៀន រៀននៅសាលាបឋមសិក្សា ទីមួយស្រុកកំណើតហ្នឹង ហៅថាភូមិក្រឡាហ្នឹង អាបឋមសិក្សាភូមិក្រឡាហ្នឹង ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាមហ្នឹង។ដល់ឆ្នាំវា កើតសង្គ្រាមហ្នឹង ប៉ាបានមករៀននៅសាលាដីដុះ កំពង់ចាមនេះបានមួយឆ្នាំដែរ គ្រាន់តែក្នុង សាលាបឋមសិក្សាដីកដុះក្រុងកំពង់ចាមនេះ បានមួយឆ្នាំហ្នឹង ហើយក៏សង្គ្រាមកើតដល់ ក៏កៀរចេញពីស្រុកភូមិអស់ទៅ។ ដូច្នេះការរៀនសូត្ររបស់ប៉ាបានអត់ចប់សាលាបឋមផង។

ក៖ កាលប៉ាឯងនៅតូច ធ្លាប់ស្រម៉ៃចង់ក្លាយជាអីដែរពេលអនាគត?

ខ៖ ប៉ានៅពីតូច ប៉ាមិនដែលនឹកស្រម៉ៃអីធំដុំទេ ប៉ាគ្រាន់តែនឹកស្រម៉ៃថា កើតមកជាតិ ហ្នឹងដូចចង់ធ្វើពេទ្យ បើសិនជារៀនសូត្រចេះដឹងអីចង់ធ្វើពេទ្យ ប៉ុន្តែវាមិនបានរៀនសូត្រ ចេះដឹង មិនបានធ្វើពេទ្យ វាបានត្រឹមធ្វើតែជាអ្នករកស៊ីធម្មតា ដូចរាស្រ្តដទៃទៀតហ្នឹង។

ក៖ អីចឹង ប៉ាឯងធ្លាប់ធ្វើស្រែ ឬធ្លាប់ធ្វើចម្ការអីដែរ?

ខ៖ រឿងស្រែចម្ការ ដូចធ្លាប់ជួយធ្វើតាំងពីតូចៗមកម៉េះ ព្រោះថាយើងវាកើតជាកូនអ្នកស្រែ ធ្លាប់ជួយធ្វើតាំងពីឪពុកម្តាយយើង កាលយើងនៅតូចៗហ្នឹង ប៉ាធ្លាប់ធ្វើស្រែចម្ការ ប៉ុន្តែមិនបានច្រើនរាប់ហិចតានឹងគេទេ គ្រាន់តែថាវាបានចិញ្ចឹមក្រុមគ្រួសារ។

ក៖ អ៊ីចឹងប៉ាមានក្រុមគ្រួសារដែលជាអ្នករកស៊ីដែរអត់?

ខ៖ ក្រុមគ្រួសារខាងប៉ា បើខ្សែខាងកុងក្រឡាហ្នឹងវិញ អ្នកស្រែ អត់មានអ្នក ជំនួញជួញដូរ លក់អីផ្សារនឹងគេទេ។ អ្នកស្រែធ្វើចម្ការអ៊ីចឹងទៅ ចម្ការតូចតិចតួច ដាំពោត ដាំបន្លែអ៊ីចឹងទៅ ហើយចិញ្ចឹមគោ ចិញ្ចឹមក្របីអីប៉ុណ្ណឹង។

ក៖ អ៊ីចឹង ពេលប៉ាឯងការ ការនៅថ្ងៃណា ខែណា ឆ្នាំណា? ចាំ?

ខ៖ អូ! កាលប៉ាការដូចជាឆ្នាំ...មើល... ថ្ងៃ១៦ ខែ៣ ឆ្នាំ១៩៨៧ ។

ក៖ ការនៅណា?

ខ៖ ការនៅខាងផ្ទះខាងប្រពន្ធ គេហៅថាភូមិដំណាក់ព្រីង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។

ក៖ ពេលប៉ាឯងការហ្នឹង ការដោយស្រឡាញ់គ្នាឬក៏ឪពុកម្តាយអ្នករៀបចំឱ្យ?

ខ៖ កាលសម័យណុង បើសិនជាវាយើងនិយាយពីរឿងការរៀបការ អ្នកខ្លះគេរៀបការ ដោយស្រឡាញ់គ្នាទៅ។ អ្នកខ្លះគេរៀបការដោយឪពុកម្តាយ គេផ្សំផ្គុំឱ្យ រៀបចំឱ្យចឹង បើប៉ាចូលទៅខាងប្រភេទចាស់ៗ ឪពុកម្តាយរៀបចំឱ្យ។ ប៉ាអត់ដែលស្គាល់ម៉ែពីមុនមក ផងហ្នឹង ទើបតែស្គាល់ថ្ងៃការតែម៉ងណុង។

ក៖ អ៊ីចឹង ប៉ាឯងជួបម៉ែលើកដំបូងថ្ងៃការហ្មងចឹង ឬក៏មុនៗការហ្នឹងបានជួបគ្នា ជួបគ្នាលើកដំបូងថ្ងៃណា?

ខ៖ ហ្នែ៎! ជួបលើកដំបូងដូច...ដូចជាចាស់ៗហៅទៅលេងស្រុកខាងណុងម្តង រួចប៉ាមានគិតចាប់អារម្មណ៍មើលថាទៅ...អី ទៅលេងណុង ដល់ពេលទៅបានគេនិយាយពីរឿង រៀបចំស្តីដណ្តឹង រៀបចំមង្គលការអីក៏... យល់ព្រមទៅតាមចាស់ៗទៅ។

ក៖ អ៊ីចឹងពេលប៉ាឯងការមានបណ្តាការការអីទៅដេស?

ខ៖ អើ! ពេលការហ្នឹង វាមិនមែនជាធំដុំរបៀបដូចជាឧកញ៉ាអីឥឡូវទេ ប៉ុន្តែវាជាលក្ខណៈ យើងជាប្រជាជនសាមញ្ញ វាតែងតែមានហើយ ដំណើរការជំនូនជំនួយ លើកទឹកចិត្តអី ហ្នឹង។ វាមិនមែនដៃទទេសោះ ហើយក៏វាមិនមែនអីក៏ធំដុំដែរ។

ក៖ ហើយជីវិតប៉ាតាំងកាលពីអតីតកាល ហើយនិងបច្ចុប្បន្នហ្នឹង វាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

ខ៖ ប៉ាគិតថាជីវិតកាលពីក្មេងយើងរស់នៅជាមួយឪពុកម្តាយ ក្រោមការដឹកនាំរបស់ឪពុកម្តាយ ថែរក្សារបស់ឪពុកម្តាយ ក៏វាមួយបែបទៅយ៉ាងសុខសប្បាយម្យ៉ាងទៅ ហើយដល់ពេលធំឡើងក៏យើងជួយធ្វើការងារគាត់ រកស៊ីចិញ្ចឹមក្រុមគ្រួសារយើងចឹងទៅ ដល់ពេលយើងរៀបចំការ ជាមានប្តីប្រពន្ធហើយ យើងទៅរស់នៅបែកពីគាត់ ខិតខំធ្វើការរកស៊ីដោយខ្លួនឯង ហើយ យើងមានជីវភាពរស់នៅជាលក្ខណៈគ្រួសារមួយថ្មីទៀត ដូចជាមិនសូវអីពិបាក ហើយក៏មិនសូវអីងាយស្រួលប៉ុន្មានដែរ មួយល្មមដូចគេ ដូចអ្នកឯងចឹង។

ក៖ ប៉ាចូលចិត្តម្ហូបអី?

ខ៖ «សើច» បើចូលចិត្តរឿងម្ហូប វាជាសាមញទេ  ស៊ីគ្រាន់តែថារបស់មិនឆ្ងាញ់ក៏ស៊ីបាន របស់ឆ្ងាញ់ក៏ស៊ីបាន ឲ្យតែគេស៊ីកើត ប៉ាស៊ីកើត។ បើថាឲ្យចូលចិត្ត ប៉ាចូលចិត្តជាទូទៅ

ធម្មតា។

ក៖ អ៊ីចឹងប៉ាឯងចេះធ្វើម្ហូបដែរ?

ខ៖ តែម្ហូប... ដូចថាធន់អន់ ប៉ាធ្វើកើត ប៉ុនបើធន់ហាង ហៅថាលំដាប់អី ភោជនីអាហារអីណាភោជនីយដ្ឋានអី ប៉ាអត់ចេះធ្វើទេ ប៉ុនបើថាលក្ខណៈគ្រួសារ ប៉ាធ្វើកើត។

ក៖ អ៊ីចឹងប៉ាឯងរៀនចេះធ្វើម្ហូបពីពីណាគេ?

ខ៖ ចេះទីមួយ យើងទៅជួយឪពុកម្តាយ យើងចេះតែចេះពីម្តាយចឹងហើយ ដល់ពេលប៉ារស់នៅបែកពីគាត់ទៅ យើងសួរអ្នកជិតខាងចាស់ៗអីដែលគេធ្លាប់ចេះធ្វើហ្នឹង ហើយយើងមិនទាន់ចេះ ដូចជាសម្លរអី មានផ្សំគ្រឿងអ៊ីចឹង ចាស់ៗជួយ បង្ហាត់បង្ហាញយើងទៅ អ្នកជិតខាងហ្នឹង ។

កៈ ពេលទំនេរប៉ាឯងចូលចិត្តធ្វើអី?

ខៈ បើកាលពីក្មេង ច្រើនមានពេលទំនេរ ប៉ាចូលចិត្តស្តាប់ភ្លេង ស្តាប់ចម្រៀងអីចឹង មើលកុន អី អីចឹងទៅ។ ហើយដល់ឥឡូវ ចាស់ហើយ គ្មានពេលទំនេរទេ ទំនេរតែពេល ដេកលក់ទេ ។

កៈ ហើយប៉ាឯងចូលចិត្តទៅលេងកន្លែងណាដែរ?

ខៈ រឿងចូលចិត្ត ប៉ាមានបំណងបីកាលពីមុនហ្នស ប៉ាថា ទីមួយចង់ទៅលេងអង្គរវត្ត ទីពីរ ចង់ទៅលេងនៅទឹកសមុទ្រ នៅសមុទ្រ ទីបីចង់ជិះកាប៉ាល់ហោះម្តង។ដល់ឥឡូវប៉ា បានទៅ ដល់អង្គរវត្តបានពីរដងហើយ ប៉ាមិនទាន់បានទៅដល់សមុទ្រទេ ហើយកកាប៉ាល់ហោះ ប៉ាក៏ មិនដែលបានជិះដែរ ។

កៈ តើប៉ាចូលចិត្តល្បែងប្រជាប្រិយអីគេ?

ខៈ ល្បែងប្រជាប្រិយ វាចេះតែចូលចិត្តហើយ តាមលក្ខណៈជាតិយើងពីមុនមក ប៉ុន្តែវាមិនដែលបានលេងហ្នឹងគេ ចេះតែបានមើលក្នុងទូរទស្សន៍អីហ្នឹង គេលេងរបាំនេះ របាំនោះ ច្រៀងរាំ អីចឹងទៅ គេលេងទាញព្រ័ត្រ ចោលឈូងអី ប៉ាចូលចិត្តណាស់។

កៈ ហើយប៉ាឯងចូលចិត្តចម្រៀងបែបណា?

ខៈ រឿងចម្រៀងហ្អែស?

កៈ ចម្រៀង!

ខៈ អូ! ចម្រៀង ប៉ាមិនចូលចិត្តអីឲ្យប្រាកដប្រជា ប៉ុនថាអីក៏ប៉ាចូលចិត្តដែរ ឱ្យតែវាមាន លក្ខណៈហៅថាអប់រំ លក្ខណៈហៅថាស្លូតបូត នាំឲ្យចិត្តយើងសប្បាយ។ ប៉ាចូលចិត្តតែ អារែងរឿងចម្រៀងណា ឬក៏រឿងណាដែលនាំចូលចិត្តយើងសប្បាយ ឲ្យមានបញ្ញាតាម គេហ្នាស។

កៈ ខ្ញុំចង់ឱ្យប៉ាឯងរៀបរាប់ពីជីវិតនៅអាសម័យជំនាន់ ប៉ុល ពត?

ខៈ ជីវិតជំនាន់ប៉ុលពតគឺហាក់ដូចជាជីវិតមួយដែលយើងមិនដែលជួបប្រទះ។ បើយើងនិយាយប្រាប់ក្មេងឥឡូវ ក៏គេមិនសូវជឿដែរ។ ជីវិតរស់នៅក្រោមហៅថាការដឹកនាំរបស់ អង្គការ។ វាមិនមែនជាម្ចាស់ខ្លួនយើងទេ អង្គការគេម្ចាស់លើយើង។ គេចង់ឲ្យយើងធ្វើអី យើងធ្វើហ្នឹង គេចង់ឲ្យយើងបានហូបអី យើងបានហូបអាហ្នឹង។ គេចង់ឲ្យយើងអត់ យើងអត់ ។ យើងហាក់

ដូចជាឧបករណ៍របស់អង្គការចឹង។ យើងគ្មានសេរីភាពក្នុងការតវ៉ា គ្មានសេរីភាព អី រកខុសត្រូវអីទេ តែហ៊ានតមាត់ ត...អាវែងក្ដីអីជាមួយអង្គការ អង្គការ យកទៅសម្លាប់ចោល គ្មានមើលម៉ោងទេ ។ ដូច្នេះយើងមិនមែនជាម្ចាស់ជីវិតយើងទេ អង្គការគេសម្រេចជោគវាសនា ជីវិតយើងឲ្យយើង ។ ប៉ុនបើយើងនិយាយទៅវាវែងឆ្ងាយ វាមិនចង់និយាយ វាប៉ះពាល់ដល់គេ គ្រាន់តែដឹងក្នុងរឿងចិត្តថា ហាក់ដូចជាទាសករមួយ រស់នៅក្នុងរបបមួយដែលខ្មៅងងឹត

ហ្នឹង។

កៈ នៅពេលជំនាន់ប៉ុលពតហ្នឹង ប៉ាមានជួបព្រឹត្តិការណ៍អ្វីខ្លះ?

ខៈ អូ! រឿងព្រឹត្តិការណ៍វាព្រឹត្តិការណ៍រន្ធត់ តក់ស្លុតហើយ ប៉ុន្តែសំណាងល្អដែរ ប៉ារស់នៅ មិនសូវជា ជួបប្រទះធ្លាក់ទៅក្នុងអាវែងហៅថាអំពើភ័យ អំពើយង់ឃ្នង កាប់សម្លាប់អីចឹង ដូចសុខសប្បាយម្យ៉ាងទៅដែរ យើងគ្រាន់តែវានឿយហត់ក្នុងកិច្ចការងារ នឿយហត់នៅក្នុង ស្រេកឃ្លាន នៅក្នុងអាវែងហៅថាម្ហូបអាហារអីប៉ុណ្ណឹង។ កាលសម័យហ្នឹងយើងមិនអាចរស់ នៅដូចសម័យនេះទេ ស៊ីក៏មិនឆ្អែត ដេកក៏មិនពេញភ្នែក។

កៈ ចឹងក្រោយពីជំនាន់ប៉ុលពតមក ប៉ាសល់សាច់ញាតិណាខ្លះ?

ខៈ ក្រោយពីជំនាន់ប៉ុលពតមកនៅសល់សាច់ញាតិច្រើនដែរ ហើយអ្នកដែលស្លាប់ក៏ស្លាប់ច្រើនដែរ វាដូចថា...មើលនៅសល់បានយាយក្រោយហ្នឹង នៅសល់ឪពុកម្ដាយ ហើយប្អូនៗទាំងអស់គ្នា ហើយពូមីងខ្លះក៏មាននៅសល់មួយពីរ ខ្លះក៏ស្លាប់ទៅ។

កៈ ចឹងក្រោយពីជំនាន់ប៉ុលពតហ្នឹង ប៉ាឯងប្រកបមុខរបរអី?

ខៈ ក្រោយពីជំនាន់ប៉ុលពតមក ប៉ាមានអាយុ១៩ឆ្នាំ។ ចូលរៀនវិញមួយសារទៀតក៏ដូចជា វាជ្រុល ហើយគ្រួសារក្រីក្រយើងជួយធ្វើការឪពុកម្ដាយទៅ ដូចជាធ្វើស្រែអីចឹងទៅ ខែវស្សា។ ខែប្រាំងយើងឡើងត្នោត យកទឹកត្នោតលក់ យកស្ករលក់អីចឹងទៅ ផ្សំលុយទិញម្ហូបអាហារទ្រទ្រង់សេដ្ឋកិច្ចគ្រួសារហ្នឹង។

កៈ ចឹងសម្រាប់ជីវិតប៉ាឯងតាំងពីក្មេងរហូតដល់ឥឡូវ មានរឿងអីដែលប៉ាចាំជាងគេ?

ខៈ រឿងដែលប៉ាចាំជាងគេមួយជីវិតនេះគឺរឿងរួចផុតពីរបបប៉ុលពត។ ល្ងាចហ្នឹង យើង... ដូចថាថ្ងៃប៉ុន្មានទេ...ថ្ងៃហ្នឹងដូចជាថ្ងៃ៥ មកករាហ្នឹងហើយ គេរំដោះទីរួមខេត្តខាងកំពង់ចាម ទឹកដី

ខាងកំពង់ចាមមុន។ ហើយពួកប៉ុលពតហ្នឹងគេរសាត់បាត់ឆ្ងាយ គេដេញទៅម្ខាងទៅ។ ប៉ាហាក់ដូចមានអារម្មណ៍ថាខ្លួនប៉ាដូចស្រាល ដូចជាគេដោះអម្រែកចេញពីស្មា ហាក់ដូចជា ថាយើងបានកើតម្តងទៀត រស់នៅ សាងជីវិតថ្មីម្តងទៀត។

ក៖ ពេលក្រោយពីការរៀប...ប៉ារៀបការហើយ មានកូនប៉ុន្មាននាក់?

ខ៖ ក្រោយប៉ារៀបការហើយ វាកូនម្តងមួយៗយូរៗទៅ បូកសរុបទៅ ៥នាក់ «សើច» ស្រី២ ប្រុស៣ «សើច» ។

ក៖ មានឈ្មោះអីខ្លះ?

ឡ៖ កូនទីមួយ ប្រុស ឈ្មោះហៅថា ឡេង ភក្តី។ កូនទីពីរ ស្រី ឈ្មោះ ឡេង ធារី ។ កូនទី៣ ស្រី ឡេងធារី ដែលកំពុងតែសួរប៉ាហ្នឹងហើយ។ កូនទីបួនឈ្មោះ ឡេង តារ៉ា ហើយកូន៣៧ ឈ្មោះ ឡេង ពរជ័យ ។ «សើច»

ក៖ ប៉ាមានកូនចិញ្ចឹមអត់?

ខ៖ ប៉ាគ្មានកូនចិញ្ចឹម គ្មានកូនធម៌អីទេ ប៉ាមានតែកូនបង្កើត៥នាក់ហ្នឹង។

ក៖ ចឹងប្រពន្ធប៉ាឈ្មោះអី?

ខ៖ ប្រពន្ធប៉ាឈ្មោះ ទន់ ចាន់លី ប៉ាហៅថាតែយាយប៊ុំៗ។ «សើច»

ក៖ រួចម៉ែគាត់មានចរិកបែបណា?

ខ៖ ម៉ែមានចរិកបែបរាង ជួនណាស្រួល ជួនណាមិនស្រួល ដូចថាតាមរលកបរិយាកាស។ «សើច»

ក៖ ហើយឥឡូវម៉ែគាត់ប្រកបមុខរបរអី?

ខ៖ ម៉ែគាត់ប្រកបមុខរបរដាំស្លនៅផ្ទះ ថែទាំកូនចៅ ការងារនៅតែក្នុងផ្ទះហ្នឹង គាត់មិនអាច ទៅ ...ឲ្យទៅខាងក្រៅបានទេ ព្រោះថា ទីមួយគាត់មិនសូវរៀនសូត្របានច្រើន។ ទីពីរយើងតែមានផ្ទះ មានកូនអីចឹង វាជាប់ជើង ជាប់អីនៅហ្នឹង យើងមិនអាចទៅណាមកណាតាមចិត្ត យើងបានទេ ។

កៈ តើប៉ាចិញ្ចឹមនិងអប់រំកូនៗទាំងអស់ដោយរបៀបណា?

ខៈ ប៉ាចិញ្ចឹមកូន អប់រំកូនតាមរបៀបហៅថាផ្លូវកណ្ដាល ។ ក្ដៅក៏មិនក្ដៅ ត្រជាក់ក៏មិនត្រជាក់ មានន័យថាយើងមិនអាចប្រើអំពើហិង្សាទៅលើកូន ហើយក៏យើងមិនអាច ហៅថាលួងលោមកូនហ្នឹង ដោយពាក្យសម្ដីផ្អែមល្ហែមហ្នឹងពេក ក៏មិនដែលក៏អីចឹងទៅ ក៏យើង ដូចថា វាយ គម្រាមវាខ្លះទៅ តិចតួចទៅ ដោយរំពាត់អីទៅ។

កៈ ប៉ា... តើប៉ាមានឲ្យកូនទៅទទួលការសិក្សាដែរឬទេ?

ខៈ អូ! បើនិយាយពីការទទួលសិក្សាហ្នឹងវាវិសេសវិសាលហើយ ព្រោះថាសម័យនេះវាមាន សន្តិភាពនៅក្នុងប្រទេស កូនក្មេងតែ៦ឆ្នាំឡើងប៉ាយកទៅចូលសាលាបឋម ចូលសាលារៀន ហើយ។ មិនឲ្យមានក្រៅសាលាទេ។

កៈ ហេតុអីបានប៉ាបញ្ជូនកូនៗទាំងអស់ឲ្យទៅរៀន?

ខៈ ព្រោះថាការរៀនសូត្រវាវិសេសវិសាលសម្រាប់មនុស្ស។ កាលដែលប៉ានៅពីតូចក៏ប៉ារៀនដល់ធំឡើងអីចឹងប៉ាមានកូនទៅ ក៏ត្រូវតែទៅរៀន ព្រោះការរៀនសូត្រគឺជាការ អារែងអភិវឌ្ឍខ្លួនយើង កែលម្អខ្លួនយើង ទៅថ្ងៃអនាគតទៅយើងគេចេះដឹង យើងវារស់នៅដោយសុខសប្បាយ ។

កៈ តើនៅពេលដែលក្រុមគ្រួសារជួបនៅ... អូ... តើប៉ា...ប៉ាធ្វើម៉េចដើម្បីឲ្យក្រុមគ្រួសារមានសុភមង្គល?

ខៈ ពាក្យថាសុភមង្គលគឺសេចក្ដីសុខ សេចក្ដីចម្រើន។ ការរស់នៅល្អ សុខសប្បាយ និងរីកចម្រើន ហើយធ្វើការបានជ័យជំនះ។ បើសិនជាយើងចង់បានសេចក្ដីសុខ សេចក្ដីចម្រើន ចង់ធ្វើការបានជ័យជំនះ យើងត្រូវតែប្រព្រឹត្តទៅតាមអ្នកចេះដឹង សេពគប់ជាមួយអ្នកចេះដឹង មានន័យថាបើយើងដើរតាមអ្នកចេះ យើងនឹងបានឡើងតាមគេអ្នកចេះ ។ បើយើងដើរតាម ជាមួយអ្នកល្ងីតល្ងង់ ឬក៏យើងវាអន់ថយទៅដែរ។ ដូចេះសំខាន់ណាស់ ការរៀនសូត្រ មនុស្សម្នាក់ៗត្រូវតែរៀន កុំថាចាស់ កុំថាក្មេង។

កៈ នៅពេលដែលគ្រួសារមានបញ្ហា តើប៉ាមានវិធីអីខ្លះដើម្បីដោះស្រាយ?

ខ៖ អាហ្នឹងយើងមើលទៅតាមទំហំវាណុងដែរ តើស្ថានការហ្នឹងវាធ្ងន់ធ្ងរ ស្ថានការហ្នឹង វាធំដុំអី យើងប្រើមធ្យោបាយត្រជាក់ ហើយក៏ប្រើមធ្យោបាយក្ដៅ ក៏ប្រើតាម...អី វាទៅតាមបញ្ហាជាក់ស្ដែង។ យើងមិនអាចនិយាយបានថា អូ! ទាល់តែមានលុយ អូ! ទាល់តែមានកម្លាំង អូ! ទាល់តែមានបញ្ញាមិនមែនទេ។ វាស្ថិតនៅលើការសម្របសម្រួល ស្ថិតនៅលើការ បត់បែន ទៅតាមកាលទេសហ្នឹង ។

ក៖ តើគ្រួសារមានអត្ថន័យយ៉ាងណាចំពោះប៉ា?

ខ៖ អូ! គ្រួសារសំខាន់សម្រាប់ជីវិតប៉ា។ បើនិយាយទៅវាជាតំណពូជ តាំងពីកុងក្រឡា មកគាត់ស្រលាញ់កូនចៅ ហើយមកកុង ហ៊ុនហ្នឹង ក៏អ៊ីចឹង។ គាត់ស្រលាញ់ប៉ា មិនដែលបានវាយប៉ាម្ដងសោះ មិនដែលបានជេរប្រទេចទេ គ្រាន់តែមានតែពាក្យអប់រំល្អៗ ប៉ុនវាសំណាងល្អដែរប៉ា...វាជាកូន ហៅថាកូនស្ដាប់បង្គាប់បន្តិច បានជាឪពុកស្រឡាញ់ ហើយបានជារស់នៅវាមិនសូវជួបប្រទះបញ្ហា ទុក្ខលំបាកអី ។ ហើយដល់មកប៉ាមានកូនចៅ កូនក្រោយក៏អ៊ីចឹង ក៏ស្រឡាញ់តតាមគ្នា។ អប់រំវាទៅតាមលក្ខណៈហៅថា ការរៀនសូត្រ អប់រំវាទៅតាម សតិបញ្ញារបស់យើង ឲ្យវាដើរនៅលើផ្លូវល្អ ផ្លូវត្រូវហ្នឹង ។

ក៖ ប៉ាមានបទពិសោធន៍ដែលល្អៗនៅក្នុងជីវិតចង់ចែកចាយឲ្យកូនចៅជំនាន់ក្រោយបានដឹងខ្លះ?

ខ៖ ប៉ាមិនសូវមានការចេងចាំបទពិសោធន៍អីច្រើនទេ ប៉ុនប៉ាដឹងថា បើសិនជាយើង... ថ្ងៃក្រោយយើងចង់បានសេចក្ដីសុខ បានសេចក្ដីសប្បាយ ក៏ត្រូវតែ... យើងរៀន។ ទីមួយ យើងរៀនទៅ យើងស្គាល់ពីអ្វីនៅជុំវិញខ្លួន អ្វីដែលនៅខាងមុខ អ្វីដែលត្រូវធ្វើដំណើរទៅ អ្វីដែលត្រូវជៀសវាង ប៉ុណ្ណឹងយើងអាចដឹងហើយថាសេចក្ដីសុខ និងសេចក្ដីចម្រើនវានៅត្រង់ ណា ហើយថាសេចក្ដីជំនឿវានៅត្រង់ណា។

ក៖ អ៊ីចឹងតើប៉ាមានដំបូន្មានអីខ្លះចង់ផ្ដាំផ្ញើរដល់កូនចៅជំនាន់ក្រោយ?

ខ៖ ប៉ាគ្រាន់តែចង់និយាយថាសារសំខាន់នៃគ្រួសារគឺវាសំខាន់នៅលើឪពុកម្ដាយ ជីដូនជីតាហ្នឹងឯង ហៅថាពូជហ្នឹង...ពាក្យខ្មែរគេហៅថាពូជ។ បើសិនជាយើងប្រព្រឹត្តល្អ ដឹងគុណឪពុកម្ដាយ ស្គាល់ខុសស្គាល់ត្រូវ កូនយើងមកក៏វាឃើញលក្ខណៈដែលឪពុកម្ដាយយើង ធ្វើក៏វាធ្វើតាមហ្នឹងទៅ។ បើយើងប្រព្រឹត្តអំពើអបាយមុខ កូនហ្នឹងវាក៏ស្គាល់អំពើអបាយហ្នឹងដែរ ធ្លាក់ចូលទៅក្នុងហ្នឹង។ អ៊ីចឹងបានថាឪពុកម្ដាយជាគម្រូ បាទ ហើយចំណែកកូនចៅគឺជាអ្នកដើរ

តាមក្រោយយើង អ្នកត្រងត្រាប់ពីយើង។ ដល់មកយើងឲ្យឥទ្ធិពលអ្វីទៅគ្នា គឺគ្នាទទួលពី យើង ទៅតែប៉ុនណុង។

ក៖ ហើយនៅចុងបញ្ចប់ហ្នឹង ខ្ញុំសូមថ្លែងអំណរគុណដល់ប៉ាសម្រាប់ការសម្ភាសនៅក្នុងថ្ងៃនេះ ហើយអ្វីៗទាំងអស់នេះកូនចៅរបស់ប៉ាបានដឹងនិងបានឮនៅប្រវត្តិសាស្ត្ររបស់ប៉ា ហើយពួកយើងនឹងដាក់ចូលការសម្ភាសនេះទៅក្នុងវេបសាយខាងលើ។ សូមអរគុណ៕